**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និងប្រាក់សោធនជូនចៅក្រម និងព្រះរាជអាជ្ញា ដែលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និងព្រះរាជអាជ្ញាដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការអនុវត្តន៍បើកប្រាក់សោធនចំពោះមន្ត្រីរាជការ ដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់អំពីអត្រាភាគទាន ដែលជាកាតព្វកិច្ចត្រូវបង់ដោយរាជរដ្ឋាភិបាលនិងមន្ត្រីរាជការស៊ីវិល សម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) ដើម្បីបង្កើតឱ្យមានប្រភពធនធានផ្ទាល់មួយច្បាស់លាស់ សម្រាប់អនុវត្តគោលនយោបាយរបបសន្តិសុខសង្គមឱ្យមានប្រសិទ្ធភាព។

## ជំពូកទី២
## ការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់ ប.ជ.ស.

**មាត្រា ២.-**

កាតព្វកិច្ចបង់ភាគទានសម្រាប់ទ្រទ្រង់ ប.ជ.ស. ទៅតាមអត្រាភាគទានលើបៀវត្សរ៍សរុបប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលទាំងអស់ត្រូវបានកំណត់ ដូចខាងក្រោម៖

១- រាជរដ្ឋាភិបាល ១៨% (ដប់ប្រាំបីភាគរយ)

២- មន្ត្រីរាជការស៊ីវិល ៦% (ប្រាំមួយភាគរយ)។

មន្ត្រីរាជការស៊ីវិលទាំងអស់ត្រូវបង់ភាគទានចាប់ពីថ្ងៃចូលធ្វើការដំបូង។ ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអតីតភាពការងារគ្រប់ ៣០ឆ្នាំហើយ មិនត្រូវបង់ភាគទានទៀតទេ។

អត្រាភាគទានលម្អិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអាណាព្យាបាលនៃ ប.ជ.ស.

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៣.-**

និយោជក និងនិយោជិតនៃសហគ្រាសសាធារណៈ ដែលកន្លងមកបានបង់ភាគទានជូនរាជរដ្ឋាភិបាល ត្រូវបង់បន្តទៀត ហើយរាជរដ្ឋាភិបាលត្រូវបង្វែរភាគទាននេះ មក ប.ជ.ស. តាមអត្រាភាគទានដូចមន្ត្រីរាជការស៊ីវិល រហូតដល់មានបទប្បញ្ញត្តិថ្មី។

**មាត្រា ៤.-**

អនុក្រឹត្យនេះ ត្រូវអនុវត្តចំពោះចៅក្រមនិងព្រះរាជអាជ្ញា ដូចមន្ត្រីរាជការស៊ីវិលដែរ រហូតដល់មានបទប្បញ្ញត្តិថ្មី។

**មាត្រា ៥.-**

ចំពោះមុខ រាជរដ្ឋាភិបាលទទួលបន្ទុករ៉ាប់រងនូវចំណែក នៃប្រាក់ភាគទានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ ស្របតាមមាត្រា៣៦ នៃអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រហូតដល់មានបទប្បញ្ញត្តិថ្មី។

**មាត្រា ៦.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបើកផ្តល់ថវិកាជូនបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលតាមនីតិវិធីហិរញ្ញវត្ថុ នៅរៀងរាល់ត្រីមាសនីមួយៗ ឱ្យបាន១៥ថ្ងៃមុនត្រីមាសប្រតិបត្តិការ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ (មករា) ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**